# សិលាចារឹកគោកកន្ដាំង K.1260

គោកកន្ដាំង ឬ គោកតាំង គឺជាគោកមួយក្នុងចំណោមគោកទាំងបី(គោកខ្មោច គោកចាន់ និងគោកកន្ដាំង)ដែលនៅទិសអាគ្នេយ៍វត្តប្រាសាទមុនីសោមសាន់ ស្ថិតនៅក្នុងភូមិជ្រៃត្បូង ឃុំកៀនសង្កែ ស្រុកសូត្រនិគម ខេត្តសៀមរាប។ គោកនេះស្ថិតនៅចម្ងាយ ៥០០ម៉ែត្រខាងកើតភូមិជ្រៃត្បូង ៤០០ម៉ែត្រខាងត្បូងគោកខ្មោច និង២០០ម៉ែត្រ ខាងត្បូងគោកចាន់។ ទីនោះជាទីទួលប្រាសាទឥដ្ឋ មានបល្ល័ង្កធ្វើអំពីថ្មភក់មួយមានចារសិលាចារឹកចំនួន២បន្ទាត់។ គោកកន្ដាំងមានព័ទ្ធដោយកសិន្ធុទឹកមួយ[1]។

បល្ល័ង្កថ្មនោះ ត្រូវបានអ្នកស្រុកយកទៅកែច្នៃធ្វើជាត្បាល់ត្បៀងសម្រាប់ប្រើប្រាស់ ប៉ុន្តែក្រោយមកដោយសារមានសមាជិកគ្រួសារមានជំងឺតម្កាត់ ក៏យកថ្មនេះមកទុកនៅទីតាំងដើមវិញដដែល។ លុះក្រោយមក នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២០ ព្រះចៅអធិការវត្តប្រាសាទមុនីសោមសាន់ ព្រះនាម ប៉ក់ មួន បានប្រមែប្រមូលព្រះសង្ឃ កូនសិស្សវត្ត យកសិលាចារឹកនេះមករក្សាទុកក្នុងបរិវេណវត្ត[2]។

នៅផ្នែកខាងលើដែលចារអត្ថបទសិលាចារឹក មានរូបកងរង្វង់រាសីចក្រសម្គាល់ទីតាំងផ្កាយនិងពេលវេលានៃការប្រតិស្ឋានរូបបដិមាមួយអង្គ ដូចមានបង្ហាញក្នុងសិលាចារឹក។ ផ្នែកអក្សរចារឹកវិញ មានដាច់បាត់តួអក្សរខ្លះដោយសារមានការបែកផ្នែកខាងៗនៃផ្ទៃថ្ម ជាហេតុនាំឱ្យផ្នែកខ្លះអាចពុំបាន។ ប៉ុន្តែជាសំណាងល្អ យើងអាចបំពេញបន្ថែមចំណុចដែលបែកដាច់បាត់នោះ ដោយសារកិច្ចការរបស់ក្រុមការងារធ្វើផែនទីស្ថានីយ៍បុរាណវិទ្យានៃប្រទេសកម្ពុជា[3] ដែលបានផ្ដិតសំណៅសិលាចារឹកនេះមុនពេលខូចខាត។ កន្លងមក សិលាចារឹកនេះមិនទាន់មានការសិក្សាបោះពុម្ពផ្សាយនៅឡើយ បើទោះបីជាមានចុះលេខបញ្ជីសារពើភណ្ឌសិលាចារឹក K.1260 យូរមកហើយក្ដី។

---

[1] សូមមើល៖ https://cisark.mcfa.gov.kh/core/showsite.php?id=1956&keyword=

[2] សូមថ្លែងអំណរព្រះគុណដល់សាមណេរ យ៉េង សម្ផស្ស ដែលបានផ្ដល់ព័ត៌មានអំពីសិលាចារឹកនេះ។

[3] *Carte interactive* des *sites archéologiques khmers* ហៅកាត់ថា cisark ។

អត្ថបទដោយ៖ ហ៊ិន ឈុនតេង

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

សិលាចារឹកដ៏ខ្លីនេះ ចារឹកអំពីបុណ្យរបស់អាចារ្យ **ហរិបាលរាណត** ដែលជាចៅរបស់អាចារ្យ **ចន្ទ្រាធិបតី** មកពីស្រុកបុស្សរីគ្រាម បានប្រតិស្ឋានបដិមា**ព្រះ ស្រីធរណេន្ទ្រិសួរ** នៅឆ្នាំ៩៦៨នៃមហាសករាជ ត្រូវនឹងគ.ស.១០៤៦។ បន្ទាប់មកជាការជូនពរដល់អ្នកឯណា ដែលបានចូលរួមចម្រើនបុណ្យនិងបូជាព្រះរបស់លោកអាចារ្យដែលបានកសាងនោះ សូមឱ្យបានសោយនូវសម្បត្តិសួស្ដីតាំងពីលោកនេះរហូតបានដល់និព្វាន។

## អត្ថបទដើមជាអក្សរខ្មែរទំនើប

១-៩៦៨គក ៩មាសិ ៤រោចមាគ្គ៌គិរតជាបុប្យមឃន(ក្សត្រ)[[គុក្រពារ]]លគ្នអាយិកុម្ភគិនុស្ថាបណាកម្រតេងអញជគតគ្រី[ធរ]ណេន្ទ្រិគួរ បុន្យអា(ចាយ៌្យ) [[ហរិបាល]]

២-[[រាណ]]តិចៅអាចាយ៌្យចន្ទ្រាធិបតីស្រុកបុប្បរីគ្រាមនៅអ្នកពទ្ធ៌បូជាព្រះនេះលេងអ្នកនោះស្វេយសំបតិស្វស្តិឥហលោកល្ហេះទៅតស្វាគ៌មោក្ស[[និព្វាណ--បិ]]

## អត្ថបទសម្រួលជាភាសាខ្មែរទំនើប

ឆ្នាំ៩៦៨មហាសករាជ(១០៤៦គ.ស.) (កន្លងបាន)៩ខែ ថ្ងៃ៤រោច ខែមិគសិរចូលខែបុស្ស មឃនក្សត្រ ថ្ងៃសុក្រ លគ្ននៅឯកុម្ភរាសី គឺនូវ(វេលានោះបាន)ស្ថាបនាគម្តែងអញជគត**ស្រីធរណេន្ទ្រិសួរ** ជាបុណ្យរបស់អាចារ្យ **ហរិបាលរាណត** ជាចៅរបស់អាចារ្យ **ចន្ទ្រាធិបតី** នៅស្រុកបុស្សរីគ្រាម។ នៅអ្នក(ណា)ដែលចម្រើន(បុណ្យនិង)បូជាព្រះនេះ សូមអ្នកនោះសោយសម្បត្តិសួស្តីក្នុងលោកនេះលុះរហូតដល់សួគ៌មោក្សនិព្វាន។

តាមរយៈសិលាចារឹកនេះ បង្ហាញយើងឱ្យឃើញថា អ្នកឯណាដែលគ្រាន់តែថែរក្សាបុណ្យដែលបានកសាងរួចហើយនោះ ក៏នឹងបានបុណ្យកុសលនឹងម្ចាស់បុណ្យ បានសោយនូវសេចក្ដីសួស្ដី ចម្រើនរុងរឿង ទាំងក្នុងលោកនេះនិងលោកខាងមុខ។ សិលាចារឹកនេះបានពញ្ញាក់ស្មារតីយើងគ្រប់គ្នាត្រូវចូលរួមថែរក្សាកេរមរតក ឬបុណ្យរបស់ដូនតាដែលលោកបានកសាងបន្សល់ទុកមក ដើម្បីបានបុណ្យកុសលផង និងការពារបេតិកភណ្ឌរបស់ជាតិយើងផង។ ដូច្នេះ ការបំផ្លិចបំផ្លាញក្នុងរូបភាពណាមួយដូចជាការជួញដូរ ការកែច្នៃប្ដូររូបរាង ឬកម្ទេចចោល ជាការខុសនឹងផ្នែកជំនឿផង និងផ្នែកច្បាប់ផង។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

# បញ្ជីរូបភាព



បល្ល័ង្គមានសិលាចារឹកមកពីគោកកន្ដាំង



បល្ល័ង្គមានសិលាចារឹកដែលអ្នកស្រុកច្នៃជាត្បាល់ត្បៀង

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



អត្ថបទសិលាចារឹកនៅលើបល្ល័ង្កថ្ម



សំណៅផ្តិតសិលាចារឹក K.1260 ផ្តិតដោយ ហ៊ុន ឈុនតេង

## ឯកសារយោង

CISARK,

https://cisark.mcfa.gov.kh/core/showsite.php?id=1956&keyword=

អត្ថបទដោយ៖ ហ៊ុន ឈុនតេង